# វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- សង្គ្រាមពាណិជ្ជកម្មបង្កើនសន្ទុះការនាំចេញកម្ពុជា
- ធនាគារជប៉ុនរក្សាអត្រាការប្រាក់អវិជ្ជមាន បន្ទាបទស្សនវិស័យអត្រាអតិផរណា
- ការទទួលបានការងារនៅអាមេរិក សម្រេចបានលើសការរំពឹងទុកនៅក្នុងខែតុលា

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### សង្គ្រាមពាណិជ្ជកម្មបង្កើនសន្ទុះការនាំចេញកម្ពុជា

ការនាំចេញរបស់កម្ពុជាទៅអាមេរិក បានហក់ឡើងដល់២,៨៦ ប៊ីលានដុល្លារ(២៧%) ក្នុង៩ខែដំបូងក្នុងឆ្នាំនេះ បើយោងតាមទិន្នន័យពាណិជ្ជកម្មអន្តរជាតិ ដែលចេញផ្សាយដោយការិយាល័យជំរឿននៅអាមេរិកក្នុងសប្តាហ៍នេះ។ អាមេរិកបាននាំចេញទំនិញដែលមានតម្លៃសរុបប្រមាណ ៣២២លានដុល្លារចូលមកប្រទេសកម្ពុជា ដែលតួលេខនេះកើនឡើង១២%បើធៀបទៅនឹងឆ្នាំ២០១៧។

ទីប្រឹក្សាផ្នែកពាណិជ្ជកម្ម បានសន្និដ្ឋានថាកំណើនការនាំចេញនេះកើនឡើងដោយសារសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន។ ការដាក់ពន្ធនាំចូលលើទំនិញរបស់ចិនទៅសហរដ្ឋអាមេរិក បានធ្វើអោយមានភាពអំណោយផលចំពោះតម្លៃនៃការនាំចេញរបស់កម្ពុជា ។

**តារាងប្រចាំសប្តាហ៍៖** ថវិកាសារពើពន្ធជាតិសរុបសម្រាប់ឆ្នាំ ២០១៩

តារាងក្នុងសប្តាហ៍នេះបង្ហាញពីទំនោរនៃសារពើពន្ធសរុបសំខាន់ៗ នៅក្នុងក្របខណ្ឌថវិកាជាតិពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩ គិតជាភាគរយធៀបនឹងផ.ស.ស។ ចំណូលក្នុងប្រទេសថវិការដ្ឋបានកើនឡើងពី១៧,១%នៃផ.ស.ស ក្នុងឆ្នាំ២០១៤ ដល់១៨,៧%ក្នុងឆ្នាំ ២០១៨ ហើយត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់១៩,៣% ក្នុងឆ្នាំ២០១៩។

ក្នុងរយៈពេលដូចគ្នា ការចំណាយជាតិសរុបក៏បានកើនឡើងពី ២១,៧% ដល់២៤,៧%ផងដែរ។

អតិរេកចរន្តបានធ្លាក់ចុះពី៤,៤% ក្នុងឆ្នាំ២០១៧ ទៅ២,៤%ក្នុងឆ្នាំ ២០១៨ ប៉ុន្តែត្រូវបានគ្រោងថានឹងកើនឡើងម្តងទៀតទៅដល់ ២,៨%នៅឆ្នាំបន្ទាប់។ ឱនភាពថវិកាសរុបបានកើនឡើងក្នុងកម្រិតខ្ពស់បំផុតក្នុងរយៈពេល៥ឆ្នាំ ដែលស្មើនឹង៥,៨%ក្នុងឆ្នាំ

២០១៨ ប៉ុន្តែត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះដល់៥,៤%ក្នុងឆ្នាំ ២០១៩។

**ថវិកាជាតិ គិតជាចំណែកនៃផ.ស.ស (ឆ្នាំ២០១៤ដល់២០១៨)**




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ព័ត៌មាន និងទិន្ន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ធនាគារជប៉ុនរក្សាអត្រាការប្រាក់អវិជ្ជមាន និង បន្ទាបទស្សនវិស័យអត្រាអតិផរណា

នៅក្នុងកិច្ចប្រជុំគោលនយោបាយរូបិយវត្ថុនាខែតុលានេះ ធនាគារជប៉ុនបានសម្រេចរក្សាទុកនូវអត្រាការប្រាក់រយៈពេលខ្លីរបស់ខ្លួនអោយនៅត្រឹម ដកសូន្យក្បៀសមួយភាគរយ(-0,១%) ចំណែកឯគោលដៅរយៈពេលវែងទៅលើអត្រាការប្រាក់របស់សញ្ញាណប័នរាជរដ្ឋាភិបាល(Government Bond) ជប៉ុនដែលមានរយៈពេល ១0ឆ្នាំគឺសូន្យភាគរយ(0%)។ ធនាគារជប៉ុននឹងបង្កើនការទិញមូលបត្រភាគហ៊ុនពាណិជ្ជកម្ម(ETFs) ដែលមានតម្លៃចំនួន៦ទ្រីលានយ៉េន ព្រមទាំងការវិនិយោគលើមូលបត្រអចលនវត្ថុ(J-REITs) ចំនួន៩0ប៊ីលានយ៉េនជាប្រចាំឆ្នាំ។ ម្យ៉ាងវិញទៀត ធនាគារជប៉ុនបានរក្សានូវផលបត្រពាណិជ្ជកម្ម(Commercial Paper) ដែលមានទំហំទឹកប្រាក់ចំនួន២,២ទ្រីលានយ៉េន នឹងមូលបត្របំណុលចំនួន៣,២ទ្រីលានយ៉េន។

សេដ្ឋកិច្ចរបស់ជប៉ុននៅតែបន្តកើនឡើង ក្នុងពេលដែលអត្រាអតិផរណាបានកើនឡើងទៅកាន់២% តាមគោលដៅ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានការធ្លាក់ចុះបន្តិចបន្តួច ពោលគឺការព្យាករណ៍ទៅលើអត្រាអតិផរណាសម្រាប់ខែមីនាឆ្នាំ២០១៩ ត្រូវបានបន្ទាបពី១,១%ទៅ0,៩% ក្នុងពេលដែលអត្រាជាមធ្យមប្រចាំឆ្នាំសារពើពន្ធ២០១៩ ត្រូវបានរំពឹងទុកនៅកម្រិត១,៤%។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ការទទួលបានការងារនៅអាមេរិក សម្រេចបានលើសការរំពឹងទុកនៅក្នុងខែតុលា

យោងតាមការិយាល័យស្ថិតិពលកម្មអាមេរិក ការងារចំនួន ២៥០ 000ត្រូវបានបន្ថែមនៅក្នុងខែតុលា ដែលការរំពឹងទុកមានត្រឹមតែ២00 000។ ការងារបន្ថែម ស្ថិតនៅក្នុងផ្នែកគាំពារទាំសុខភាព កម្មន្តសាល សំណង់ ដឹកជញ្ជូន និងឃ្លាំង។ អត្រានិកម្មភាពគឺស្មើនឹង៣,៧%។

អត្រានៃការចូលរួមក្នុងទីផ្សារពលកម្មបានកើនឡើងបន្តិចពី ៦២,៧%នៅក្នុងខែកញ្ញាទៅ ៦២,៩% ប៉ុន្តែមានការប្រែប្រួលតិចតួចក្នុងរយៈពេលមួយឆ្នាំ។

## ព័ត៌មានសម្រាប់សប្ដាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្ដាហ៍ខាងមុខនេះ រួមមាន៖ ការសម្រេចកំណត់អត្រាការប្រាក់របស់ប្រទេសថៃ ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្ដាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨

- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិត របស់ប្រទេសជប៉ុន សម្រាប់ខែតុលា
- ទិន្នន័យការលក់រាយរបស់ប្រទេសសិង្ហបុរី សម្រាប់ខែកញ្ញា
- ទិន្នន័យការវិនិយោគដោយផ្ទាល់ពីបរទេសរបស់ប្រទេសហ្វីលីពីន សម្រាប់ខែសីហា

- ទិន្នន័យការលក់រាយរបស់ប្រទេសម៉ាឡេស៊ី សម្រាប់ខែកញ្ញា

<u>ថ្ងៃអង្គារ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨</u>

- តម្លៃនាំចេញ/នាំចូលរបស់ប្រទេសកូរ៉េខាងត្បូង ក្នុងខែតុលា
- កំណើនកម្ចីរបស់ប្រទេសចិន សម្រាប់ខែតុលា
- អត្រាអតិផរណារំពឹងទុករបស់អាមេរិក សម្រាប់ខែតុលា

<u>ថ្ងៃពុធ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨</u>

- របាយការណ៍ថវិកាប្រចាំខែរបស់អាមេរិក សម្រាប់ខែតុលា
- អត្រានិកម្មភាពរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែតុលា
- ផ.ស.ស. របស់ប្រទេសជប៉ុនសម្រាប់ត្រីមាសទី៣ ការប៉ាន់ស្មានដំបូង ឆ្នាំ២០១៨
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ប្រទេសថៃ
- ទិន្នន័យការវិនិយោគដោយផ្ទាល់ពីបរទេស របស់ប្រទេសចិន សម្រាប់ខែតុលា
- អត្រាអតិផរណារបស់អាមេរិក សម្រាប់ខែតុលា

<u>ថ្ងៃព្រហស្បតិ៍ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨</u>

- ការវិនិយោគមូលបត្របំណុលបរទេសរបស់ប្រទេសជប៉ុន សម្រាប់ថ្ងៃទី ១០ខែវិច្ឆិកា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែតុលា
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់ របស់ប្រទេសឥណ្ឌូនេស៊ី
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់ របស់ប្រទេសហ្វីលីពីន
- តម្លៃការនាំចេញ/ចូលរបស់អាមេរិក សម្រាប់ខែតុលា
- ទិន្នន័យការលក់រាយរបស់អាមេរិក សម្រាប់ខែតុលា

<u>ថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨</u>

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសសិង្ហបុរី សម្រាប់ខែតុលា
- អត្រាកំណើនផ.ស.ស.របស់ទីក្រុងហុងកុង សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- អត្រានិកម្មភាពរបស់ទីក្រុងហុងកុង សម្រាប់ខែតុលា
- ផលិតកម្មឧស្សាហកម្មរបស់អាមេរិក សម្រាប់ខែតុលា
- ផលិតកម្មកម្មន្តសាលរបស់អាមេរិក សម្រាប់ខែតុលា